# ឯកសារទស្សនទាន

# សិក្ខាសាលាថ្នាក់តំបន់ ស្តីពី សេរីភាពនៃការបញ្ចេញមតិ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធប្រព័ន្ធឌីជីថល

កាលបរិច្ឆេទ៖ ថ្ងៃសុក្រ ទី១០ ខែមីនា ឆ្នាំ២០២៣
ម៉ោង៖ ៨:០០ ព្រឹក ដល់ម៉ោង ១៦:៣០ រសៀល
ទីកន្លែង៖ ក្រុងបាត់ដំបង

## ១. សាវតា

បច្ចេកវិទ្យាឌីជីថល បានផ្លាស់ប្តូរទម្រង់ ឬមធ្យោបាយនៃការអនុវត្តន៍ និងការការពារសិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ប្រជាពលរដ្ឋ ដូចជា សេរីភាពនៃការបញ្ចេញមតិ និងសិទ្ធិឯកជនភាព។ សិទ្ធិឌីជីថល អនុញ្ញាតឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់ បង្កើត និងផ្សព្វផ្សាយតាមរយៈឧបករណ៍ និងបណ្តាញទំនាក់ទំនងអេឡិចត្រូនិក។ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិត និងទូរស័ព្ទដៃឆ្លាតនៅក្នុងប្រទេសកម្ពុជាបានហក់ឡើងខ្ពស់នៅប្រមាណមួយទស្សវត្សចុងក្រោយនេះ។ គិតត្រឹមឆ្នាំខែតុលា ឆ្នាំ២០២២ ប្រទេសកម្ពុជាមានអ្នកភ្ជាប់ជាមួយនឹងអ៊ីនធឺណិតប្រមាណ ១៧.៨២ លាននាក់ (internet subscribers) ដែលចំនួននេះ ច្រើនជាងចំនួនប្រជាពលរដ្ឋសរុបប្រមាណ ១៦ លាននាក់[1]។ ស្របពេលជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដើម្បីរៀបចំ និងឆ្លើយតបទៅនឹងដំណើរការនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដែលមានសសរស្តម្ភសំខាន់ចំនួន០៣គឺ ពលរដ្ឋឌីជីថល រដ្ឋាភិបាលឌីជីថល និងធុរកិច្ចឌីជីថល។ ដើម្បីសម្រេចបាននូវគោលដៅខាងលើ រាជរដ្ឋាភិបាលបានអនុម័តនូវប្រកាស អនុក្រឹត្យ និងរៀបចំសេចក្តីព្រាងច្បាប់មួយចំនួនផ្សេងទៀតដែលពាក់ព័ន្ធនឹងឌីជីថល រួមមានអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វាអ៊ីនធឺណិតជាតិ សេចក្តីព្រាងច្បាប់ស្តីពី សន្តិសុខសាយប័រ សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពី ការការពារទិន្នន័យ (Data Protection Law)។

ការអនុម័ត និងការវិវឌ្ឍន៍ក្របខណ្ឌច្បាប់ថ្មីពាក់ព័ន្ធនឹងឌីជីថលខាងលើ បានបង្កើតឱ្យមានក្តីព្រួយបារម្ភពីសំណាក់អង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងការរិតត្បិតសេរីភាពបញ្ចេញមតិ សិទ្ធិជួបជុំ និងសិទ្ធិឯកជនភាពនៅលើប្រព័ន្ធអ៊ីនធឺណិត។ ជាពិសេស ប្រសិនបើការអនុម័តច្បាប់ខាងលើ មិនបានពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយអង្គការសង្គមស៊ីវិល និងមិនបានអនុលោមតាមគោលការណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័ន និងទទួលស្គាល់។ យោងតាមក្របខណ្ឌច្បាប់ជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ សេរីភាពជាមូលដ្ឋាន ដែលរួមមាន សេរីភាពខាងការបញ្ចេញមតិ សេរីភាពនៃការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិឯកជនភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបគួរត្រូវបានការពារ និងលើកកម្ពស់។

[1] Khmer Time News: https://www.khmertimeskh.com/501197606/internet-users-at-17-82-million-in-october/

សិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបគឺ ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ដែលក្នុងន័យនេះមាត្រា ៤១ ចែងថា៖

"ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ"។

ទន្ទឹមនឹងមាត្រា៤១ អំពីសេរីភាពខាងការបញ្ចេញមតិនេះ មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញក៏មានចែងសិទ្ធិចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋខ្មែរដោយចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ"។

ដោយឡែកនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិវិញ សេរីភាពបញ្ចេញមតិត្រូវបានធានាដោយមាត្រា១៩ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា១៩ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានចែងថា៖ "មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ"។

លក្ខណៈពិសេសរបស់រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ឆ្នាំ១៩៩៣ បន្ទាប់ពីកិច្ចព្រមព្រៀងស្តីពីសន្តិភាពទីក្រុងប៉ារីស៍ គឺនៅត្រង់មាត្រា៣១ ដែលទទួលស្គាល់នូវច្បាប់សិទ្ធិមនុស្សជាសកល ដោយមាត្រា៣១ នេះចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយណាទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនេះបញ្ជាក់ឱ្យឃើញថាប្រទេសកម្ពុជា គឺទទួលស្គាល់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ ជាផ្លូវការដែលទទួលស្គាល់នូវបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្ស។

## ២. គោលបំណង

- ដើម្បីលើកកម្ពស់ការយល់ដឹងដល់អ្នកចូលរួមស្តីពីគោលការណ៍សេរីភាពបញ្ចេញមតិ និងការបញ្ចេញមតិលើអ៊ីនធឺណិត និងប្រព័ន្ធឌីជីថល។
- លើកម្ពស់ចំណេះដឹង និងផ្សព្វផ្សាយដល់អ្នកចូលរួមឱ្យបានសិក្សាឈ្វេងយល់បន្ថែមទៀតនូវក្របខណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងសិទ្ធិឌីជីថល រួមមាន អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វាអ៊ីនធឺណិតជាតិ សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន។

## ៣. អ្នកចូលរួម

សិក្ខាកាមចូលរួមនៅក្នុងសិក្ខាសាលានេះមានចំនួនសរុប ៤០-៥០ នាក់ ដែលជាសមាជិកនៃអង្គការ គ.ស.ក ផ្ទាល់ បណ្តាញសម្របសម្រួលនៃអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត អង្គការថ្នាក់មូលដ្ឋាន (CBOs) ព្រមទាំងបណ្តាសមាគម និងអង្គការដៃគូសង្គមស៊ីវិលមួយចំនួន។


www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

## ៤. សេចក្តីព្រាងរបៀបវារៈ

| ពេលវេលា | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៧:៣០ – ៨:00 | ចុះឈ្មោះអ្នកចូលរួម | លោក ផេង សេង |
| ៨:00 – ៨:១០ | ប្រកាសហេតុ និង គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា | លោកស្រី ប្រាក់ កែវ គង្គា |
| ៨:១០ – 0៨:២០ | មតិស្វាគមន៍ លោកស្រី **រស់ ឆវីច័ណ្ណា** នាយិកាប្រតិបត្តិ អង្គការក្រុមទ្រទ្រង់ភូមិ (VSG) និងជាប្រធានបណ្តាញសម្របសម្រួលនៃអង្គការមិនមែនរដ្ឋាភិបាល ខេត្តបាត់ដំបង | លោកស្រី ប្រាក់ កែវ គង្គា |
| ៨:២០ – 0៨:៣០ | សុន្ទរកថាស្វាគមន៍ និងបើកកម្មវិធីដោយ អ្នកស្រី **ស៊ិន ពុទ្ធារី** នាយិកាប្រតិបត្តិនៃ គ.ស.ក | លោកស្រី ប្រាក់ កែវ គង្គា |
| ៨:៣០ – 0៨:៤0 | ការធ្វើតេស្តមុនវគ្គ | អ្នកចូលរួមទាំងអស់គ្នា |
| ៨:៤0 – ១0: 00 | បទបង្ហាញស្តីពី "គោលការណ៍ទូទៅនៃសេរីភាពបញ្ចេញមតិ និងសេរីភាពបញ្ចេញមតិលើអ៊ីនធឺណិត"។ | លោក ស ម៉ូរី ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិ |
| ១0:00 – ១0: ១៥ | សម្រាកអាហារស្រេន់ | អ្នកចូលរួមទាំងអស់គ្នា |
| ១0:១៥ – ១១:៣0 | លក្ខខណ្ឌនៃការកំរិតសេរីភាពបញ្ចេញមតិ និងគោលការណ៍សេរីភាពអ៊ីនធឺណិត | លោក ស ម៉ូរី ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិ |
| ១១:00 – ១២:00 | ការពិភាក្សាក្រុមលើករណីសិក្សា | អ្នកចូលរួមទាំងអស់គ្នា |
| ១២:00 – ១៣:៣0 | ពិសារអាហារថ្ងៃត្រង់រួមគ្នា | អ្នកចូលរួមទាំងអស់គ្នា |
| ១៣:៣0 – ១៣:៤0 | ល្បែងថាមពល | |
| ១៣:៤0 – ១៤:00 | ការធ្វើបទបង្ហាញតាមក្រុម | អ្នកចូលរួមទាំងអស់គ្នា |
| ១៤:00 – ១៥:00 | ការធ្វើបទបង្ហាញស្តីពី ការវិវឌ្ឍន៍ក្របខណ្ឌច្បាប់ថ្មីៗពាក់ព័ន្ធនឹងសិទ្ធិឌីជីថល រួមមាន៖<br>• អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វាអ៊ីនធឺណិតជាតិ<br>• សេចក្តីព្រាងច្បាប់ស្តីពី បទល្មើសបច្ចេកវិទ្យាព័ត៌មាន<br>• សេចក្តីព្រាងច្បាប់ស្តីពី សន្តិសុខសាយប័រ | លោក ស ម៉ូរី ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិ |
| ១៥:00 – ១៥:២0 | សម្រាកពិសារអាហារសម្រន់ | អ្នកចូលរួមទាំងអស់គ្នា |
| ១៥:២0 – ១៦:00 | ការពិភាក្សាក្រុម អំពីមតិយោបល់ និងការយល់ឃើញរបស់អ្នកចូលរួមចំពោះការវិវឌ្ឍន៍ក្របខណ្ឌច្បាប់ថ្មីៗពាក់ព័ន្ធនឹងសិទ្ធិឌីជីថល | អ្នកចូលរួមទាំងអស់គ្នា |
| ១៦:00 – ១៦:២0 | ការធ្វើតេស្តក្រោយវគ្គ និងបំពេញទម្រង់វាយតម្លៃ | អ្នកចូលរួមទាំងអស់គ្នា |
| ១៦.២0 - ១៦.៣0 | បូកសរុបលទ្ធផល និងបិទកម្មវិធី | តំណាងប្រធានបណ្តាញថ្នាក់ខេត្ត |

*__កំណត់សម្គាល់៖__ អ្នករៀបចំកម្មវិធីសូមថតរូប វីដេអូ ឬសម្លេងសម្រាប់ការអប់រំផ្សព្វផ្សាយ និងកត់ត្រាកំណត់ហេតុ និងសូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈខាងលើតាមការចាំបាច់ ។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងអ្នករៀបចំកម្មវិធី ៕